# អនុសញ្ញាអន្តរជាតិ

# ស្តីពី

# ការបំបាត់រាល់ទម្រង់ នៃ
# ការរើសអើងប្រឆាំងនឹងស្ត្រីភេទ



Downloaded from http://www.khmerlaws.com

Downloaded from http://www.khmerlaws.com

# អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើង
# ប្រឆាំងនឹងស្ត្រីភេទ

អនុម័តនិងបើកឱ្យចុះហត្ថលេខា ឱ្យសច្ចាប័ននិងឱ្យចូលជាសមាជិក
តាមសេចក្តីសម្រេចចិត្តលេខ ៣៤/១៨០ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ១៩៧៩ របស់មហាសន្និបាតអង្គការសហប្រជាជាតិ

ចូលជាធរមាននៅថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ១៩៨១ ស្របតាមបទបញ្ញត្តិមាត្រា ២៧ (១)

***រដ្ឋភាគីនៃអនុសញ្ញានេះ***

*កត់សំគាល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិអះអាងជាថ្មី នូវជំនឿលើសិទ្ធិមូលដ្ឋានរបស់ មនុស្ស លើសេចក្តីថ្លៃថ្នូរ និងតម្លៃមនុស្ស និងលើសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី ។

*កត់សំគាល់ឃើញថា* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បញ្ជាក់នូវគោលការណ៍មិនរើសអើង និងបានប្រកាសថា មនុស្សគ្រប់រូបកើតមកមានសេរីភាពនិងសមភាព ក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ ហើយថាមនុសគ្រប់រូប ត្រូវទទួលបានសិទ្ធិនិងសេរីភាពទាំងអស់ ដែលមានចែងក្នុងសេចក្តីប្រកាសនោះ ដោយគ្មានការប្រកាន់បែងចែកណាមួយ រួមមានការបែងចែកខាងផ្លូវភេទផង ។

*កត់សំគាល់ឃើញថា* រដ្ឋភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស មានកាតព្វកិច្ចធានាសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី ក្នុងការអាស្រ័យផលសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ពលរដ្ឋ និងនយោបាយ ។

*យល់ឃើញ* អនុសញ្ញាអន្តរជាតិ ដែលបានអនុម័តក្រោមកិច្ចឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា ក្នុងការលើកស្ទួយសមភាពនៃសិទ្ធិរវាងបុរសនិងស្ត្រី ។

*កត់សំគាល់ឃើញ* សេចក្តីសម្រេចចិត្ត សេចក្តីប្រកាស និងអនុសាសន៍នានា ដែលបានអនុម័តដោយអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា ក្នុងគោលបំណងលើកស្ទួយសមភាពនៃសិទ្ធិរវាងបុរសនិងស្ត្រី ។

*មានកង្វល់ថា* ទោះបីមានលិខិតុបករណ៍ទាំងនេះហើយក្តី ក៏ការរើសអើងដ៏រីករាលដាលប្រឆាំងនឹងស្ត្រីភេទ នៅតែបន្តកើតមាន ។



Downloaded from http://www.khmerlaws.com

*រំលឹកឡើងវិញថា* ការរើសអើងប្រឆាំងនឹងស្ត្រីភេទ រំលោភលើគោលការណ៍សមភាពនៃសិទ្ធិ និងការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាឧបសគ្គដល់ការចូលរួមរបស់ស្ត្រី ក្នុងល័ក្ខខ័ណ្ឌស្មើភាពគ្នាជាមួយបុរសក្នុងជីវភាពនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌នៃប្រទេសរបស់ខ្លួន ធ្វើឱ្យរាំងស្ទះដល់ការរីកចម្រើននៃភាពសំបូណ៌រុងរឿងរបស់សង្គម និងគ្រួសារ ហើយបង្ករឧបសគ្គដល់ការអភិវឌ្ឍន៍ពេញលេញនៃសត្តានុភាពរបស់ស្ត្រី ក្នុងការបម្រើប្រទេសរបស់ខ្លួន និងមនុស្សជាតិ ។

*មានកង្វល់ថា* ក្នុងស្ថានភាពក្រីក្រ ស្ត្រីភេទបានទទួលតិចបំផុតនូវម្ហូបអាហារ សេវាសុខាភិបាល ការអប់រំ ការហ្វឹកហ្វឺន និងឱកាសរកការងារធ្វើ ហើយនិងសេចក្តីត្រូវការដទៃទៀត ។

*ជឿជាក់ថា* ការបង្កើតប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិថ្មី ផ្អែកលើមូលដ្ឋានសមភាពនិងយុត្តិធម៌ នឹងរួមចំណែកយ៉ាងសំខាន់ដល់ការលើកស្ទួយសមភាពរវាងបុរសនិងស្ត្រី ។

*គូសបញ្ជាក់ថា* ការលុបបំបាត់ចោលរបបអាប៉ាថេត គ្រប់ទម្រង់ពូជសាសន៍និយម ការរើសអើងពូជសាសន៍ អាណានិគមនិយម អាណានិគមនិយមបែបថ្មី ការឈ្លានពាន ការកាន់កាប់ និងជិះជាន់ដោយបរទេស និងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ គឺជាការចាំបាច់ដល់ការអាស្រ័យផលពេញលេញពីសិទ្ធិរបស់បុរសនិងស្ត្រី ។

*អះអាងថា* ការពង្រឹងសន្តិភាព និងសន្តិសុខអន្តរជាតិ ការបន្ធូរភាពតានតឹងអន្តរជាតិ សហប្រតិបត្តិការទៅវិញទៅមករវាងរដ្ឋទាំងអស់ ដោយមិនគិតដល់ប្រព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចរបស់រដ្ឋទាំងនោះ ការដកហូតអាវុធជាទូទៅនិងទាំងស្រុង ជាពិសេស ការដកហូតអាវុធនុយក្លេអែរ ក្រោមការត្រួតពិនិត្យហ្មត់ចត់ និងដោយប្រសិទ្ធិភាពពីអន្តរជាតិ ការអះអាងនូវគោលការណ៍យុត្តិធម៌ សមភាព និងអត្ថប្រយោជន៍ទៅវិញទៅមក ក្នុងទំនាក់ទំនងរវាងប្រទេសទាំងឡាយ និងការសម្រេចបាននូវសិទ្ធិស្វ័យសម្រេច និងឯករាជ្យភាពរបស់ប្រជាជាតិក្រោមការជិះជាន់ និងអាណានិគមបរទេស និងការកាន់កាប់ដោយបរទេស ហើយនិងការគោរពអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី នឹងលើកស្ទួយវឌ្ឍនភាពនិងការអភិវឌ្ឍន៍សង្គម ហើយផលនេះ នឹងរួមចំណែកដល់ការធ្វើឱ្យសម្រេចបាន នូវសមភាពពេញលេញរវាងបុរសនិងស្ត្រី ។

*ជឿជាក់ថា* ការអភិវឌ្ឍន៍យ៉ាងពេញលេញរបស់ប្រទេសមួយ សុខមាលភាពរបស់ពិភពលោក និងបុព្វហេតុសន្តិភាព ត្រូវការឱ្យមានការចូលរួមជាអតិបរិមារបស់ស្ត្រី ដោយសមភាពជាមួយបុរស នៅក្នុងវិស័យទាំងអស់ ។


Downloaded from http://www.khmerlaws.com

*ចងចាំថា* វិភាគទានធំធេងរបស់ស្ត្រីចំពោះសុខមាលភាព គ្រួសារ និងការអភិវឌ្ឍន៍នៃសង្គម ដែលមិនបានទទួលស្គាល់ពេញលេញមកទល់ពេលនេះ សារសំខាន់ខាងសង្គមនៃមាតុភាព និងតួនាទីរបស់ឪពុកម្តាយក្នុងគ្រួសារ និងក្នុងការអប់រំកូន និង*ដឹងថា* តួនាទីរបស់ស្ត្រីក្នុងការបង្កើតកូន មិនគួរជាមូលហេតុនៃការរើសអើងទេ ប៉ុន្តែការអប់រំកូន តម្រូវឱ្យចែករំលែកការទទួលខុសត្រូវរវាងបុរសនិងស្ត្រី និងសង្គមទាំងមូល ។

*ដឹងថា* តួនាទីជាប្រពៃណីរបស់បុរសនិងស្ត្រីនៅក្នុងសង្គមនិងគ្រួសារ ចាំបាច់ត្រូវមានការផ្លាស់ ប្តូរ ដើម្បីធ្វើឱ្យសម្រេចបាននូវសមភាពពេញលេញរវាងបុរសនិងស្ត្រី ។

*ប្តេជ្ញាចិត្ត* អនុវត្តគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងសេចក្តីប្រកាសស្តីពីការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ហើយដើម្បីគោលបំណងនោះ អនុម័តវិធានការចាំបាច់នានា ដើម្បីលប់បំបាត់ចោលការរើសអើងគ្រប់ទម្រង់ និងគ្រប់ការសម្តែងចេញ ។

***បានព្រមព្រៀងគ្នាតទៅ :***

## ផ្នែកទី ១

### មាត្រា ១

ដើម្បីបម្រើគោលដៅនៃអនុសញ្ញានេះ ពាក្យ "ការរើសអើងប្រឆាំងស្ត្រីភេទ" សំដៅដល់ការប្រកាន់បែងចែក ការផាត់ចេញ ឬការរឹតត្បិតផ្អែកលើភេទ ដែលមានអនុភាព ឬមានបំណងធ្វើឱ្យខូចខាត ឬធ្វើឱ្យមោឃៈនូវការទទួលស្គាល់ ការអាស្រ័យផល ឬការប្រើប្រាស់ដោយស្ត្រី ដោយឥតគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រី ផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រី នូវសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាន ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងពលរដ្ឋ ឬក្នុងវិស័យដទៃទៀត ។

### មាត្រា ២

រដ្ឋភាគី ផ្តន្ទាទោសការរើសអើងប្រឆាំងស្ត្រីភេទក្នុងគ្រប់ទម្រង់ ព្រមព្រៀងគ្នាអនុវត្តគោលនយោបាយ តាមមធ្យោបាយសមស្រប និងដោយឥតពន្យាពេល ដើម្បីឈានទៅលប់បំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ ហើយក្នុងទិសដៅនេះ សន្យាថា :


Downloaded from http://www.khmerlaws.com

(ក) បញ្ចូលគោលការណ៍សមភាពរវាងបុរសនិងស្ត្រី ទៅក្នុងរដ្ឋធម្មនុញ្ញ ឬច្បាប់ជាតិសមស្រប ឯទៀត ប្រសិនបើមិនទាន់បានបញ្ចូលនៅឡើយ និងធានាតាមផ្លូវច្បាប់ ឬមធ្យោបាយសមស្របដទៃទៀត ដើម្បីធ្វើឱ្យគោលការណ៍នេះបានសម្រេចជាក់ស្តែង ។

(ខ) អនុម័តបទបញ្ញត្តិ និងវិធានការច្បាប់ និងវិធានការសមស្របផ្សេងៗ រួមមានទណ្ឌកម្មផង បើចាំបាច់ ដើម្បីហាមឃាត់ការរើសអើងទាំងអស់ប្រឆាំងនឹងស្ត្រី ។

(គ) បង្កើតកិច្ចការពារសិទ្ធិរបស់ស្ត្រីតាមផ្លូវច្បាប់ ផ្អែកលើមូលដ្ឋានសមភាពជាមួយបុរស និងធានាការពារដោយស័ក្តិសិទ្ធិដល់ស្ត្រី ប្រឆាំងនឹងអំពើរើសអើង តាមរយៈសាលាជំរះក្តីជាតិដែលមានសមត្ថកិច្ច និងស្ថាប័នសាធារណៈដទៃទៀត ។

(ឃ) ទប់មិនឱ្យធ្វើអំពើ ឬការអនុវត្តដែលមានលក្ខណៈរើសអើងប្រឆាំងនឹងស្ត្រី និងធានាថា អាជ្ញាធរ និងស្ថាប័នសាធារណៈ ធ្វើសកម្មភាពស្របតាមកាតព្វកិច្ចនេះ ។

(ង) ចាត់វិធានការសមស្របទាំងអស់ ដើម្បីលប់បំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រី ដែលធ្វើឡើងដោយបុគ្គល អង្គការ ឬសហគ្រាសណាមួយ ។

(ច) ចាត់វិធានការសមស្របទាំងអស់ រួមការធ្វើច្បាប់ផង ដើម្បីកែប្រែ ឬដាក់ឱ្យនិរាករច្បាប់ បទបញ្ជា ទម្លាប់ និងការអនុវត្តណាដែលបង្កើតការរើសអើងប្រឆាំងនឹងស្ត្រី ។

(ឆ) ដាក់ឱ្យនិរាករបទបញ្ញត្តិព្រហ្មទណ្ឌណា ដែលបង្កើតជាការរើសអើងប្រឆាំងនឹងស្ត្រី ។

## មាត្រា ៣

ក្នុងគ្រប់គ្រប់វិស័យ ជាពិសេសវិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ចនិងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចំរើនពេញលេញរបស់ស្ត្រី ដើម្បីធានាឱ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដោយសមភាពជាមួយបុរស ។

## មាត្រា ៤

១. ការអនុម័តដោយរដ្ឋភាគី នូវវិធានការពិសេសបណ្តោះអាសន្ន ដើម្បីពន្លឿនការកសាងសមភាពរវាងបុរសនិងស្ត្រី មិនត្រូវចាត់ទុកជាការរើសអើងដូចបានចែងក្នុងអនុសញ្ញានេះទេ ប៉ុន្តែទោះតាមបែបណាមួយក៏ដោយ មិនត្រូវមានន័យថា រក្សាទុកបទដ្ឋានវិសមភាព ឬដាច់ដោយឡែកឡើយ វិធាន


Downloaded from http://www.khmerlaws.com

ការទាំងនេះ ត្រូវដាក់ឱ្យនិរាករណ៍នៅពេលគោលដៅខាងសមភាពនៃឱកាស និងនៃការប្រព្រឹត្តមកលើស្ត្រី បានសម្រេចហើយ ។

២. ការអនុម័តដោយរដ្ឋភាគីនូវវិធានការពិសេស រួមមានវិធានការទាំងឡាយ ដែលមានក្នុងអនុសញ្ញានេះផង ដើម្បីការពារមាតុភាព មិនត្រូវចាត់ទុកជាការរើសអើងឡើយ ។

## មាត្រា ៥

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីៈ

(ក) កែប្រែផ្នត់គំនិតឥរិយាបថសង្គម និងវប្បធម៌របស់បុរសនិងស្ត្រី ដើម្បីសម្រេចបាននូវការលុបបំបាត់ចោលសេចក្តីលំអៀងនិងទំលាប់ និងការអនុវត្តជាទម្លាប់ផ្សេងៗទៀត ផ្អែកលើគំនិតស្តីពីភាពទាបជាង ឬខ្ពស់ជាងរបស់ភេទណាមួយ ឬលើតួនាទីជាទំលាប់សម្រាប់បុរសនិងស្ត្រី ។

(ខ) ធានាថា ការអប់រំគ្រួសារ មានរាប់បញ្ចូលការយល់ដឹងត្រឹមត្រូវអំពីមាតុភាព ដែលជាមុខងាររបស់សង្គម និងការទទួលស្គាល់ការទទួលខុសត្រូវរួមរបស់បុរសនិងស្ត្រី ក្នុងការចិញ្ចឹមកូន និងការអភិវឌ្ឍន៍របស់កូន ហើយប្រការនេះ ក៏ត្រូវមានការយល់ថា ប្រយោជន៍របស់កុមារគឺជាល័ក្ខខ័ណ្ឌចម្បងក្នុងគ្រប់ករណីទាំងអស់ ។

## មាត្រា ៦

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីបង្ក្រាបគ្រប់ទម្រង់នៃការជួញដូរស្ត្រី និងអាជីវកម្មពេស្យាកម្មលើស្ត្រី ។

# ផ្នែកទី ២

## មាត្រា ៧

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រីក្នុងជីវភាពនយោបាយនិងសាធារណៈរបស់ប្រទេស និងជាពិសេស ត្រូវធានាដល់ស្ត្រីនូវល័ក្ខខ័ណ្ឌស្មើភាពជាមួយបុរសនូវសិទ្ធិ ៖

(ក) បោះឆ្នោតនៅគ្រប់ការបោះឆ្នោត និងការធ្វើប្រជាមតិសាធារណៈ និងមានសិទ្ធិឈរឈ្មោះបោះឆ្នោតសម្រាប់អង្គការសាធារណៈ ដែលជ្រើសរើសដោយបោះឆ្នោត ។


Downloaded from http://www.khmerlaws.com

(ខ) ចូលរួមតាក់តែងគោលនយោបាយរបស់រដ្ឋ និងការអនុវត្តគោលនយោបាយ កាន់មុខការសាធារណៈ និងបំពេញមុខងារសាធារណៈ នៅគ្រប់កម្រិតជាន់ថ្នាក់របស់រដ្ឋាភិបាល ។

(គ) ចូលរួមក្នុងអង្គការ និងសមាគមក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធនឹងជីវភាពសាធារណៈ និងនយោបាយរបស់ប្រទេសជាតិ ។

## មាត្រា ៨

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីធានាឱ្យស្ត្រីមានឱកាសធ្វើជាតំណាងរដ្ឋាភិបាលនៅថ្នាក់អន្តរជាតិ និងចូលរួមក្នុងកិច្ចការរបស់អង្គការអន្តរជាតិ ដោយផ្អែកលើល័ក្ខខ័ណ្ឌស្មើភាពជាមួយបុរស និងដោយគ្មានការរើសអើង ។

## មាត្រា ៩

១. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធស្មើគ្នានឹងបុរស ក្នុងការទទួលផ្លាស់ប្តូរ ឬរក្សាទុកសញ្ជាតិរបស់ខ្លួន ។ រដ្ឋភាគី ត្រូវធានាជាពិសេសថា ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬការផ្លាស់ប្តូរសញ្ជាតិរបស់ប្តីក្នុងពេលអាពាហ៍ពិពាហ៍ មិនធ្វើឱ្យផ្លាស់ប្តូរជាស្វ័យប្រវត្តិនូវសញ្ជាតិរបស់ប្រពន្ធ មិនធ្វើឱ្យប្រពន្ធគ្មានសញ្ជាតិ ឬបង្ខំឱ្យប្រពន្ធយកសញ្ជាតិរបស់ប្តីឡើយ ។

២. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរស ក្នុងការសម្រេចពីសញ្ជាតិរបស់កូនផងដែរ ។

## ផ្នែកទី ៣

## មាត្រា ១០

រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ដើម្បីធានាឱ្យស្ត្រីមានសិទ្ធិស្មើគ្នានឹងបុរសក្នុងវិស័យអប់រំ និងជាពិសេស ដើម្បីធានាដល់ស្ត្រី ដោយផ្អែកលើមូលដ្ឋាននៃសមភាពរវាងបុរសនិងស្ត្រី នូវៈ

(ក) ល័ក្ខខ័ណ្ឌដូចគ្នាសម្រាប់មុខរបរ និងការណែនាំខាងវិជ្ជាជីវៈ សម្រាប់ការទទួលការសិក្សា និងសម្រាប់ការទទួលបាននូវសញ្ញាប័ត្រក្នុងគ្រឹះស្ថានអប់រំគ្រប់ប្រភេទ ទាំងនៅជនបទទាំងនៅទីក្រុង ។


Downloaded from http://www.khmerlaws.com

សមភាពនេះ ត្រូវធានាឱ្យមានក្នុងការអប់រំ មុនបឋមសិក្សា ការអប់រំចំណេះទូទៅ បច្ចេកទេស វិជ្ជាជីវៈ និងបច្ចេកទេសជាន់ខ្ពស់ និងការបណ្តុះបណ្តាលវិជ្ជាជីវៈមធ្យមគ្រប់ផ្នែកផងដែរ ។

(ខ) សិទ្ធិទទួលកម្មវិធីសិក្សាអប់រំដូចគ្នា ការប្រឡងដូចគ្នា បុគ្គលិកបង្រៀនដែលមានគុណសម្បត្តិដូចគ្នា និងបរិវេណ និងសម្ភារៈសិក្សាដែលមានគុណភាពដូចគ្នា ។

(គ) ការលុបបំបាត់រាល់ទស្សនៈជាទំលាប់ស្តីពីតួនាទីរបស់បុរសនិងស្ត្រីនៅគ្រប់កម្រិត និងគ្រប់ទម្រង់នៃការអប់រំ ដោយលើកទឹកចិត្តដល់ការអប់រំរួមគ្នា និងប្រភេទផ្សេងៗទៀតនៃការអប់រំ ដែលជួយឱ្យសម្រេចគោលបំណងនេះ និងជាពិសេស ដោយពិនិត្យកែប្រែឡើងវិញនូវអត្ថបទសិក្សា និងកម្មវិធីសិក្សា និងសម្របសម្រួលវិធីសាស្ត្របង្រៀន ។

(ឃ) ឱកាសដូចគ្នា ក្នុងការទទួលអាហារូបករណ៍ និងប្រាក់សម្រាប់ការសិក្សាផ្សេងៗ ។

(ង) ឱកាសដូចគ្នា ក្នុងការទទួលកម្មវិធីអប់រំអចិន្ត្រៃយ៍ រួមមានកម្មវិធីអក្ខរកម្មសំរាប់នីតិជន និងអនក្ខរៈជនផង ជាពិសេស កម្មវិធីទាំងឡាយសំដៅកាត់បន្ថយឱ្យបាន ឆាប់រហ័សតាមដែលអាចធ្វើទៅបាន នូវគម្លាតណាមួយខាងការអប់រំដែលមានរវាងបុរសនិងស្ត្រី ។

(ច) ការបន្ថយអត្រាបោះបង់ការសិក្សារបស់សិស្សស្រី និងការរៀបចំកម្មវិធីសម្រាប់យុវនារី និងស្ត្រីដែលឆាប់បោះបង់ការសិក្សា ។

(ឆ) ឱកាសដូចគ្នា ក្នុងការចូលរួមយ៉ាងសកម្មក្នុងកីឡា និងកាយសិក្សា ។

(ជ) ការទទួលបានព័ត៌មានអប់រំពិសេសជាក់លាក់ ដើម្បីជួយធានាសុខភាព និងសុខមាលភាពគ្រួសារ រួមមានព័ត៌មាន និងដំបូន្មានស្តីពីផែនការគ្រួសារផង ។

## មាត្រា ១១

១. រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងស្ត្រី ក្នុងវិស័យការងារ ដើម្បីធានា ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រី នូវសិទ្ធិដូចគ្នា និងជាពិសេស :

(ក) សិទ្ធិធ្វើការងារដែលជាសិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបានរបស់មនុស្សជាតិគ្រប់រូប ។

(ខ) សិទ្ធិមានឱកាសធ្វើការងារដូចគ្នា រួមមានការអនុវត្តល័ក្ខណៈវិនិច្ឆ័យដូចគ្នាផង ក្នុងការជ្រើសរើសឱ្យធ្វើការងារ ។


Downloaded from http://www.khmerlaws.com

(គ) សិទ្ធិជ្រើសរើសដោយសេរីនូវវិជ្ជាជីវៈ និងការងារ សិទ្ធិឡើងស័ក្តិ សិទ្ធិមានស្ថិរភាពការងារ ទទួលប្រាក់បំណាច់និងល័ក្ខខ័ណ្ឌការងារ សិទ្ធិទទួលការបណ្តុះបណ្តាលនិងវិក្រិតការខាងវិជ្ជាជីវៈ រួមមាន ការហ្វឹកហាត់ការងារ សុក្រឹតការខាងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលជាអចិន្ត្រៃយ៍ផង ។

(ឃ) សិទ្ធិក្នុងការទទួលប្រាក់បំណាច់ស្មើគ្នា រួមទាំងផលប្រយោជន៍ និងសិទ្ធិទទួលបានការគិតគូស្មើគ្នាចំពោះការងារដែលមានតម្លៃស្មើគ្នា និងសិទ្ធិទទួលបានការគិតគូស្មើគ្នា លើការវាយតម្លៃគុណភាពការងារ ។

(ង) សិទ្ធិទទួលបានសន្តិសុខសង្គម ជាពិសេសផលប្រយោជន៍សម្រាប់ការចូលនិវត្តន៍ ការគ្មានការងារធ្វើ ការមានជំងឺ ការគ្មានសុពលភាព និងជរាពាធិ ឬបាត់បង់សមត្ថភាពការងារដទៃទៀត ព្រមទាំងសិទ្ធិឈប់សម្រាកដោយមានប្រាក់ឈ្នួល ។

(ច) សិទ្ធិទទួលបានការការពារសុខភាព និងសុវត្ថិភាពក្នុងល័ក្ខខ័ណ្ឌការងារ រួមមានការការពារមុខងារបន្តពូជផង ។

២. ដើម្បីបង្ការការរើសអើងប្រឆាំងនឹងស្ត្រីផ្អែកលើអាពាហ៍ពិពាហ៍ ឬមាតុភាព និងដើម្បីធានាសិទ្ធិធ្វើការងាររបស់ស្ត្រីឱ្យបានស័ក្តិសិទ្ធិ រដ្ឋភាគីសន្យាចាត់វិធានការសមស្រប ដើម្បី ៖

(ក) ហាមឃាត់ ដោយដាក់ទណ្ឌកម្មនូវការបណ្តេញចេញពីការងារ ដោយមូលហេតុមានគភ៌ ឬការឈប់សម្រាកមាតុភាព និងការរើសអើងក្នុងការបណ្តេញចេញពីការងារ ដោយផ្អែកលើស្ថានភាពរៀបអាពាហ៍ពិពាហ៍ ។

(ខ) ផ្តល់ការឈប់សម្រាកមាតុភាពដោយមានប្រាក់ឈ្នួល ឬប្រាក់បំណាច់សង្គមកិច្ចស្មើគ្នាដោយគ្មានការបាត់បង់ការងារ អតីតភាពការងារ ឬជំនួយសង្គមកិច្ច ។

(គ) ជំរុញការផ្តល់សេវាគាំពារសង្គមកិច្ចចាំបាច់ ដើម្បីឱ្យឪពុកម្តាយ អាចបព្ចូលកាតព្វកិច្ចគ្រួសារ ជាមួយនឹងការទទួលខុសត្រូវខាងវិជ្ជាជីវៈ និងការចូលរួមក្នុងជីវភាពសាធារណៈ ជាពិសេសដោយសម្រួលដល់ការបង្កើត និងការអភិវឌ្ឍន៍បណ្តាញនៃសម្ភារៈរូបវ័ន្តសម្រាប់ថែទាំកុមារ ។

(ឃ) ផ្តល់ការការពារពិសេសដល់ស្ត្រីកំពុងមានគភ៌ ពីប្រភេទការងារទាំងឡាយណា ដែលបញ្ជាក់ឱ្យឃើញថាមានគ្រោះថ្នាក់ដល់ពួកគេ ។


Downloaded from http://www.khmerlaws.com

៣. ច្បាប់ការពារស្ត្រីទាក់ទងនឹងបញ្ហាដែលបានចែងក្នុងមាត្រានេះ ត្រូវលើកយកមកពិនិត្យឡើងវិញជាទៀងទាត់ ទៅតាមចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេស និងត្រូវសើរើ ធ្វើនិរាករ ឬអនុវត្តបន្តទៅតាមការចាំបាច់ ។

### មាត្រា ១២

១. រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ក្នុងវិស័យថែទាំសុខភាព ដើម្បីធានា ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រី នូវសិទ្ធិទទួលសេវាសុខាភិបាល រួមមានមធ្យោបាយទាក់ទងនឹងផែនការគ្រួសារផង ។

២. ក្រៅពីបទបញ្ញត្តិដែលចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ រដ្ឋភាគីត្រូវធានាដល់ស្ត្រីកំពុងមានគភ៌ កំពុងសំរាលកូន និងក្រោយពេលសំរាលកូន នូវការផ្តល់សេវាសមស្រប បើចាំបាច់ ដោយឥតគិតថ្លៃ ព្រមទាំងអាហាររូបត្ថម្ភគ្រប់គ្រាន់ក្នុងរយៈពេលមានគភ៌ និងពេលបំបៅកូន ។

### មាត្រា ១៣

រដ្ឋភាគី ត្រូវចាត់វិធានការសមស្របនានា ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ក្នុងវិស័យជីវភាព សេដ្ឋកិច្ច និងសង្គមកិច្ចផ្សេងទៀត ដើម្បីធានា ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រី នូវសិទ្ធិដូចគ្នា ជាពិសេសៈ

(ក) សិទ្ធិទទួលបានផលប្រយោជន៍សម្រាប់គ្រួសារ

(ខ) សិទ្ធិខ្ចីប្រាក់ពីធនាគារ អ៊ីប៉ូតែក និងទម្រង់ផ្សេងៗទៀតនៃឥណទានហិរញ្ញវត្ថុ

(គ) សិទ្ធិចូលរួមក្នុងសកម្មភាពកំសាន្ត កីឡា និងគ្រប់ទិដ្ឋភាពនៃជីវភាពវប្បធម៌ ។

### មាត្រា ១៤

១. រដ្ឋភាគី ត្រូវគិតគូរដល់បញ្ហាពិសេសដែលស្ត្រីនៅជនបទប្រឈមមុខ និងតួនាទីសំខាន់របស់ស្ត្រីជនបទក្នុងការរក្សាភាពគង់វង្សសេដ្ឋកិច្ចគ្រួសាររបស់ខ្លួន រួមមានការងាររបស់ពួកគេ ក្នុងផ្នែកគ្មានចំណូលសេដ្ឋកិច្ចផង ។ រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីធានាការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ ចំពោះស្ត្រីនៅជនបទ ។


Downloaded from http://www.khmerlaws.com

២. រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីនៅជនបទ ដើម្បីធានា ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រី នូវការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍ជនបទ និងទទួលអត្ថប្រយោជន៍ពីការអភិវឌ្ឍន៍ជនបទ និងជាពិសេស ត្រូវធានាឱ្យស្ត្រីជនបទទាំងនោះនូវសិទ្ធិ :

(ក) ចូលរួមពេញលេញក្នុងការតាក់តែង និងអនុវត្តផែនការអភិវឌ្ឍន៍នៅគ្រប់លំដាប់ថ្នាក់ ។

(ខ) មានសិទ្ធិទទួលបានសេវាគ្រប់គ្រាន់ខាងវិស័យសុខាភិបាល រួមទាំងព័ត៌មាន ដំបូន្មាន និងសេវាខាងផែនការគ្រួសារ ។

(គ) ទទួលអត្ថប្រយោជន៍ដោយផ្ទាល់ពីកម្មវិធីសន្តិសុខសង្គម ។

(ឃ) ទទួលបានការបណ្តុះបណ្តាលនិងការអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធគ្រប់ប្រភេទ រួមមានការអប់រំអក្ខរកម្មបង្កើតមុខរបរផង ព្រមទាំង ជាពិសេសអត្ថប្រយោជន៍ខាងសេវាសហគមន៍ និងការពន្យល់ផ្សព្វផ្សាយរបស់ថ្មី ដើម្បីបង្កើនសមត្ថភាពបច្ចេកទេសរបស់ស្ត្រី ។

(ង) រៀបចំក្រុមនិងសហករណ៍ជួយគ្នាទៅវិញទៅមក ដើម្បីឱ្យមានសិទ្ធិមានឱកាសខាងសេដ្ឋកិច្ចស្មើគ្នា តាមរយៈការងារមានប្រាក់ឈ្នួល ឬការងារឯករាជ្យ ។

(ច) ចូលរួមក្នុងគ្រប់សកម្មភាពរបស់សហគមន៍

(ឆ) មានសិទ្ធិទទួលបានឥណទាននិងប្រាក់កម្ចីខាងកសិកម្ម សេវារកទីផ្សារ បច្ចេកវិជ្ជាសមស្រប និងការគិតគូស្មើគ្នាក្នុងការកែទម្រង់ដីធ្លីនិងកសិកម្ម ព្រមទាំងក្នុងគម្រោងបែងចែកដីធ្លី ។

(ជ) អាស្រ័យផលល័ក្ខខ័ណ្ឌរស់នៅគ្រប់គ្រាន់ ជាពិសេសទាក់ទងនឹងការមានផ្ទះសម្បែង អនាម័យ ការផ្គត់ផ្គង់អគ្គិសនីនិងទឹក ការដឹកជញ្ជូន និងគមនាគមន៍ ។

## ផ្នែកទី ៤

## មាត្រា ១៥

១. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីនូវសមភាពជាមួយបុរសនៅចំពោះមុខច្បាប់ ។

២. រដ្ឋភាគី ត្រូវផ្តល់ឱ្យស្ត្រីក្នុងបញ្ហារដ្ឋប្បវេណី នូវឋានៈនីត្យានុកូលដូចគ្នានឹងបុរស និងមានឱកាសដូចគ្នាដើម្បីប្រើប្រាស់ឋានៈនេះ ។ ជាពិសេស រដ្ឋភាគីត្រូវផ្តល់ឱ្យស្ត្រីនូវសិទ្ធិស្មើគ្នាក្នុងការចុះកិច្ច


Downloaded from http://www.khmerlaws.com

សន្យា និងការគ្រប់គ្រងទ្រព្យ និងត្រូវឱ្យមានការប្រព្រឹត្តមកលើស្ត្រីដូចគ្នា ក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ និងសាលាជំរះក្តី ។

៣. រដ្ឋភាគីព្រមព្រៀងគ្នាថា កិច្ចសន្យាទាំងអស់ និងលិខិតុបករណ៍ឯកជនដទៃទៀតគ្រប់ប្រភេទដែលមានអានុភាពនីត្យានុកូល សំដៅរឹតត្បិតឋានៈនីត្យានុកូលរបស់ស្ត្រី ត្រូវទុកជាមោឃៈ ។

៤. រដ្ឋភាគី ត្រូវឱ្យបុរសនិងស្ត្រីមានសិទ្ធិដូចគ្នាចំពោះច្បាប់ ដែលទាក់ទងដល់សិទ្ធិដើរហើររបស់បុគ្គល និងសេរីភាពជ្រើសរើសនិវេសនដ្ឋាន និងលំនៅដ្ឋាន ។

## មាត្រា ១៦

១. រដ្ឋភាគី ត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី លើរាល់បញ្ហាដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ និងជាពិសេស ដោយផ្អែកលើមូលដ្ឋានសមភាពរវាងបុរសនិងស្ត្រី ត្រូវធានាឱ្យស្ត្រីនូវ ៈ

(ក) សិទ្ធិដូចគ្នាក្នុងការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ។

(ខ) សិទ្ធិដូចគ្នាក្នុងការជ្រើសរើសសហព័ទ្ធរបស់ខ្លួនដោយសេរី និងក្នុងការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ តែនៅពេលណាដែលពួកគេព្រមព្រៀងគ្នាដោយសេរី និងដោយពេញលេញប៉ុណ្ណោះ ។

(គ) សិទ្ធិនិងការទទួលខុសត្រូវដូចគ្នា នៅពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយអាពាហ៍ពិពាហ៍ ។

(ឃ) សិទ្ធិនិងការទទួលខុសត្រូវដូចគ្នាក្នុងនាទីជាឪពុកម្តាយលើបញ្ហាទាក់ទងនឹងកូន ដោយឥតគិតពីស្ថានភាពគ្រួសារ ហើយអត្ថប្រយោជន៍របស់កូនត្រូវស្ថិតជាចម្បងនៅគ្រប់ករណីទាំងអស់ ។

(ង) សិទ្ធិដូចគ្នាក្នុងការសម្រេចចិត្តដោយសេរីនិងដោយស្មារតីទទួលខុសត្រូវ ក្នុងការសម្រេចអំពីចំនួន និងការពន្យារកំណើតកូន និងក្នុងការទទួលបានព័ត៌មាន ការអប់រំ និងមធ្យោបាយដើម្បីឱ្យស្ត្រីអាចប្រើប្រាស់សិទ្ធិទាំងនេះ ។

(ច) សិទ្ធិនិងការទទួលខុសត្រូវដូចគ្នា ចំពោះការអាណាព្យាបាល ការការពារ ការគ្រប់គ្រង និងការទទួលចិញ្ចឹមកូនអ្នកដទៃ ឬក្នុងការអនុវត្តស្រដៀងគ្នានេះ បើគំនិតទាំងនេះមានស្រាប់នៅក្នុងច្បាប់ជាតិ ។ នៅគ្រប់ករណីទាំងអស់ អត្ថប្រយោជន៍របស់កូនត្រូវចាត់ទុកជាចម្បង ។


Downloaded from http://www.khmerlaws.com

(ឆ) សិទ្ធិបុគ្គលដូចគ្នារវាងប្ដីនិងប្រពន្ធ រួមមានសិទ្ធិជ្រើសរើសនាមត្រកូល វិជ្ជាជីវៈ និងមុខរបរផង។

(ជ) សិទ្ធិដូចគ្នាសម្រាប់ទាំងពីរនាក់ប្ដីនិងប្រពន្ធចំពោះកម្មសិទ្ធិ ការទិញ ការចាត់ចែង ការគ្រប់គ្រង ការអាស្រ័យផល និងការប្រគល់ទ្រព្យសម្បត្តិ ទោះដោយមិនគិតថ្លៃក្ដី ឬគិតថ្លៃក្ដី។

២. ការភ្ជាប់ពាក្យ និងការរៀបអាពាហ៍ពិពាហ៍កូន មិនត្រូវមានអានុភាពផ្លូវច្បាប់ទេ ហើយគេត្រូវចាត់វិធានការចាំបាច់ទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីកំណត់អាយុអប្បបរមា សម្រាប់រៀបអាពាហ៍ពិពាហ៍ ហើយចាំបាច់ត្រូវចុះបញ្ជីអាពាហ៍ពិពាហ៍នៅក្នុងបញ្ជីជាផ្លូវការ។

## ផ្នែកទី ៥

## មាត្រា ១៧

១. ក្នុងគោលបំណងពិនិត្យការវិវឌ្ឍន៍ទៅមុខនៃការអនុវត្តអនុសញ្ញានេះ គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីមួយ ត្រូវបានបង្កើតឡើង (ចាប់ពីនេះទៅ ប្រើត្រឹមតែពាក្យគណៈកម្មាធិការ)។ គណៈកម្មាធិការនេះ មានអ្នកជំនាញការ ១៨ រូប នៅពេលដែលអនុសញ្ញានេះចូលជាធរមាន។ បន្ទាប់ពីរដ្ឋភាគីទី ៣៥ បានឱ្យសច្ចាប័ន ឬបានចូលជាសមាជិកនៃអនុសញ្ញានេះ។ គណៈកម្មាធិការនេះ នឹងមានអ្នកជំនាញការចំនួន ២៣ រូប ដែលមានសីលធម៌ និងមានសមត្ថកិច្ចខ្ពស់ក្នុងវិស័យដែលត្រូវអនុវត្តអនុសញ្ញានេះ។ អ្នកជំនាញការ ត្រូវបោះឆ្នោតជ្រើសរើសដោយរដ្ឋភាគី ពីក្នុងចំណោមជនជាតិរបស់ខ្លួន និងត្រូវធ្វើការក្នុងឋានៈជាបុគ្គលឯកជន ដោយធ្វើការពិចារណាបែងចែកទៅតាមភូមិសាស្ត្រដោយសមធម៌ និងឱ្យមានតំណាងទម្រង់ផ្សេងៗនៃអារ្យធម៌ ព្រមទាំងទៅតាមប្រព័ន្ធច្បាប់ធំៗផង។

២. សមាជិករបស់គណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតសម្ងាត់ ពីបញ្ជីបេក្ខជនដែលស្នើដោយរដ្ឋភាគី។ រដ្ឋភាគីនីមួយៗ អាចដាក់ស្នើបេក្ខជនម្នាក់ក្នុងចំណោមជនជាតិរបស់ខ្លួន។

៣. ការបោះឆ្នោតដំបូងបង្អស់ ត្រូវធ្វើឡើង ៦ ខែ ក្រោយពីកាលបរិច្ឆេទចូលជាធរមាននៃអនុសញ្ញានេះ។ យ៉ាងតិច ៣ ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចេញលិខិតអញ្ជើញរដ្ឋភាគី ឱ្យដាក់ស្នើនាមបេក្ខជនរបស់ខ្លួនក្នុងរយៈពេល ២ ខែ។


Downloaded from http://www.khmerlaws.com

អគ្គលេខាធិការ ត្រូវរៀបចំតាមលំដាប់អក្ខរក្រម នូវបញ្ជីឈ្មោះបេក្ខជនដែលស្នើដោយរដ្ឋភាគី ដោយបញ្ជាក់ឈ្មោះរដ្ឋភាគីដែលបានជ្រើសតាំងបេក្ខជនទាំងនោះ ហើយផ្ញើបញ្ជីនេះទៅគ្រប់រដ្ឋភាគី។

៤. ការបោះឆ្នោតជ្រើសរើស ត្រូវធ្វើឡើងក្នុងសម័យប្រជុំរបស់រដ្ឋភាគី តាមការកោះអញ្ជើញដោយអគ្គលេខាធិការ នៅទីស្នាក់ការអង្គការសហប្រជាជាតិ។ កូរ៉ុមសម្រាប់កិច្ចប្រជុំគឺពីរភាគបីនៃរដ្ឋភាគី។ បេក្ខជនដែលជាប់ជាសមាជិកគណៈកម្មាធិការ ត្រូវតែជាបេក្ខជនទទួលបានសម្លេងច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាត ពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាន និងបានបោះឆ្នោត។

៥. សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតសម្រាប់រយៈពេល ៤ ឆ្នាំ។ ប៉ុន្តែ អាណត្តិសមាជិក ៩ រូប ដែលជាប់នៅពេលបោះឆ្នោតលើកទី ១ ត្រូវផុតកំណត់ក្នុងរយៈពេល ២ ឆ្នាំ ហើយឈ្មោះសមាជិកទាំង ៩ រូបនេះ ត្រូវចាប់ឆ្នោតជ្រើសរើសដោយប្រធានអង្គប្រជុំភ្លាមៗ បន្ទាប់ពីការបោះឆ្នោតលើកទី ១។

៦. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការបន្ថែម ៥ រូប នឹងត្រូវធ្វើឡើងស្របតាមបទបញ្ញត្តិច្បាប់ក្នុងកថាខណ្ឌ ២ កថាខណ្ឌ ៣ នឹងកថាខណ្ឌ ៤ នៃមាត្រានេះ បន្ទាប់ពីមានការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកលើកទី ៣៥។ អាណត្តិសមាជិក ២ រូប នៃសមាជិកបន្ថែមដែលជាប់ឆ្នោត នឹងត្រូវផុតកំណត់ក្នុងរយៈពេល ២ ឆ្នាំ ហើយឈ្មោះសមាជិកទាំង ២ រូបនេះ ត្រូវជ្រើសរើសតាមការចាប់ឆ្នោតដោយប្រធានគណៈកម្មាធិការ។

៧. ដើម្បីបំពេញកន្លែងទំនេរដោយចៃដន្យ រដ្ឋភាគីណាដែលមានអ្នកជំនាញការរបស់ខ្លួនឈប់បំពេញមុខងារជាសមាជិកគណៈកម្មាធិការ ត្រូវតែងតាំងអ្នកជំនាញការម្នាក់ទៀត ពីចំណោមជនជាតិខ្លួន ដោយមានការយល់ព្រមពីគណៈកម្មាធិការ។

៨. សមាជិកគណៈកម្មាធិការ ត្រូវទទួលថវិកា ពីធនធានរបស់អង្គការសហប្រជាជាតិ តាមចំណែកនិងល័ក្ខខ័ណ្ឌដែលកំណត់ដោយមហាសន្និបាត អាស្រ័យលើសារសំខាន់នៃការងាររបស់គណៈកម្មាធិការ។

៩. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់បុគ្គលិកនិងសម្ភារៈរូបវ័ន្តដែលចាំបាច់សម្រាប់គណៈកម្មាធិការបំពេញមុខងារឱ្យបានស័ក្តិសិទ្ធិ ស្របតាមអនុសញ្ញានេះ។


Downloaded from http://www.khmerlaws.com

## មាត្រា ១៨

១. រដ្ឋភាគី សន្យាដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីគណៈកម្មាធិការពិនិត្យនូវរបាយការណ៍ស្តីពីវិធានការខាងនីតិកម្ម តុលាការ រដ្ឋបាល ឬវិធានការផ្សេងៗ ដែលបានអនុម័តផ្តល់អនុភាពដល់បទបញ្ញត្តិនៃអនុសញ្ញានេះ ព្រមទាំងការរីកចម្រើនដែលសម្រេចបាន ៖

(ក) ក្នុងរយៈពេល ១ ឆ្នាំ ក្រោយពីការចូលជាធរមាននៃអនុសញ្ញា ចំពោះរដ្ឋដែលពាក់ព័ន្ធ។

(ខ) បន្ទាប់មក យ៉ាងហោចណាស់រៀងរាល់ ៤ ឆ្នាំម្តង និងរបាយការណ៍បន្ថែម បើមានសេចក្តីស្នើសុំរបស់គណៈកម្មាធិការ។

២. របាយការណ៍ អាចបញ្ជាក់ពីកត្តានិងការលំបាក ដែលនាំឱ្យប៉ះពាល់ដល់ការបំពេញកាតព្វកិច្ចស្របតាមអនុសញ្ញានេះ។

## មាត្រា ១៩

១. គណៈកម្មាធិការ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

២. គណៈកម្មាធិការ ត្រូវបោះឆ្នោតជ្រើសរើសមន្ត្រីការិយាល័យរបស់ខ្លួនសម្រាប់រយៈពេល ២ ឆ្នាំ។

## មាត្រា ២០

១. គណៈកម្មាធិការ ត្រូវជួបប្រជុំជាធម្មតាមិនលើសពី ២ សប្តាហ៍ក្នុងមួយឆ្នាំៗ ដើម្បីពិនិត្យរបាយការណ៍ដែលស្នើឡើងស្របតាមមាត្រា ១៨ នៃអនុសញ្ញានេះ។

២. សម័យប្រជុំគណៈកម្មាធិការ ត្រូវប្រារព្ធធ្វើជាធម្មតានៅទីស្នាក់ការនៃអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របមួយផ្សេងពីនេះ អាស្រ័យដោយការកំណត់របស់គណៈកម្មាធិការ។

## មាត្រា ២១

១. តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច គណៈកម្មាធិការត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំជូនមហាសន្និបាតនៃអង្គការសហប្រជាជាតិ អំពីសកម្មភាពរបស់ខ្លួន និងអាចផ្តល់យោបល់និងផ្តល់អនុសាសន៍ទូទៅ ផ្អែកលើការពិនិត្យរបាយការណ៍ និងព័ត៌មានដែលទទួលបានពីរដ្ឋភាគី។ ការផ្តល់យោបល់និងអនុសាសន៍ ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍របស់គណៈកម្មាធិការ អមដោយមូលវិចារណ៍របស់រដ្ឋភាគី ប្រសិនបើមាន។


Downloaded from http://www.khmerlaws.com

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនរបាយការណ៍របស់គណៈកម្មាធិការ ទៅគណៈកម្មការទទួលបន្ទុកស្ថានភាពស្ត្រី ដើម្បីជ្រាបជាព័ត៌មាន។

## មាត្រា ២២

អង្គការឯកទេស មានសិទ្ធិមានជាតំណាង នៅពេលពិនិត្យការអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ ដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន។ គណៈកម្មាធិការ អាចអញ្ជើញអង្គការឯកទេសនានា ឱ្យដាក់របាយការណ៍ស្តីពីការអនុវត្តអនុសញ្ញានេះ ក្នុងវិស័យដែលស្ថិតក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន។

## ផ្នែកទី ៦

## មាត្រា ២៣

គ្មានចំណុចណាមួយក្នុងអនុសញ្ញានេះ ធ្វើឱ្យប៉ះពាល់ដល់បទបញ្ញត្តិ ដែលនាំឱ្យសម្រេចបាននូវអត្ថប្រយោជន៍ខាងសមភាពរវាងបុរសនិងស្ត្រី ដែលអាចមានច្រើនជាងនេះ នៅក្នុង :

(ក) ច្បាប់របស់រដ្ឋភាគី ឬ

(ខ) អនុសញ្ញា សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតដែលនៅជាធរមានក្នុងរដ្ឋនោះ។

## មាត្រា ២៤

រដ្ឋភាគី សន្យាអនុម័តគ្រប់វិធានការចាំបាច់ថ្នាក់ជាតិ ដើម្បីធ្វើឱ្យសម្រេចបាននូវការប្រើប្រាស់ឱ្យបានពេញលេញ នូវសិទ្ធិទាំងឡាយ ដែលទទួលស្គាល់ក្នុងអនុសញ្ញានេះ។

## មាត្រា ២៥

១. អនុសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋទាំងអស់ចុះហត្ថលេខា។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចាត់តាំងជាអ្នកទទួលដឹកល់ទុកអនុសញ្ញានេះ។

៣. អនុសញ្ញានេះ ជាកម្មវត្ថុនៃការឱ្យសច្ចាប័ន។ លិខិតុបករណ៍នៃការឱ្យសច្ចាប័ន ត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។


Downloaded from http://www.khmerlaws.com

៤. អនុសញ្ញានេះ ត្រូវបើកចំហឱ្យរដ្ឋទាំងអស់សុំចូលជាសមាជិក។ ការសុំចូលជាសមាជិក ត្រូវធ្វើឡើងដោយការតំកល់លិខិតុបករណ៍សុំចូលរួមជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា ២៦

១. រដ្ឋភាគី អាចសុំសើរើអនុសញ្ញានេះបាននៅគ្រប់ពេលវេលា ដោយការជូនដំណឹងជាលាយល័ក្ខអក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២. មហាសន្និបាតអង្គការសហប្រជាជាតិ ត្រូវសម្រេចលើវិធានការដែលត្រូវចាត់ ប្រសិនជាមានតាមសេចក្ដីសុំនោះ។

## មាត្រា ២៧

១. អនុសញ្ញានេះ ត្រូវចូលជាធរមាននៅថ្ងៃទីសាមសិប ក្រោយកាលបរិច្ឆេទនៃតំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិកទី ២០ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២. សម្រាប់រដ្ឋនីមួយៗដែលឱ្យសច្ចាប័នលើអនុសញ្ញានេះ ឬសុំចូលជាសមាជិក ក្រោយពីការតំកល់លិខិតុបករណ៍នៃការឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិកទី ២០ អនុសញ្ញានេះនឹងត្រូវចូលជាធរមាន នៅថ្ងៃទីសាមសិប ក្រោយកាលបរិច្ឆេទនៃការដាក់តំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិករបស់ខ្លួន។

## មាត្រា ២៨

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវទទួល និងផ្សព្វផ្សាយដល់រដ្ឋទាំងអស់ នូវអត្ថបទល័ក្ខខ័ណ្ឌដែលរដ្ឋបានធ្វើ នៅខណៈពេលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក។

២. ល័ក្ខខ័ណ្ឌដែលមិនស្របតាមកម្មវត្ថុនិងគោលបំណងនៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតឱ្យធ្វើឡើយ។

៣. ល័ក្ខខ័ណ្ឌទាំងឡាយអាចដកចេញទៅវិញបាននៅគ្រប់ពេលវេលា ដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវជូនដំណឹងនេះបន្តដល់រដ្ឋទាំងអស់។ ការជូនដំណឹងជាលាយលក្ខអក្សរ ត្រូវមានប្រសិទ្ធិភាពនៅថ្ងៃដែលបានទទួល។


Downloaded from http://www.khmerlaws.com

## មាត្រា ២៩

១. រាល់វិវាទរវាងរដ្ឋភាគីពីរ ឬច្រើនជាងនេះ ស្តីពីការបកស្រាយ ឬការអនុវត្តអនុសញ្ញានេះ ដែលមិនអាចដោះស្រាយតាមរយៈការចរចារបាន ត្រូវដាក់ឱ្យមានការសម្រេចដោយអាជ្ញាកណ្តាល តាមសំណើររបស់ភាគីណាមួយនៃគូវិវាទនេះ ។ បើក្នុងរយៈពេល ៦ ខែ គិតចាប់ពីថ្ងៃស្នើឱ្យមានអាជ្ញាកណ្តាល ភាគីវិវាទមិនឯកភាពលើការរៀបចំអាជ្ញាកណ្តាលទេ ភាគីណាមួយនៃភាគីវិវាទទាំងនោះ អាចលើករឿងវិវាទទៅតុលាការយុត្តិធមិអន្តរជាតិ តាមសេចក្តីសុំស្របតាមលក្ខន្តិកៈរបស់តុលាការ ។

២. រដ្ឋភាគីនីមួយៗ នៅពេលចុះហត្ថលេខា ឬឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកនៃអនុសញ្ញានេះ អាចប្រកាសថា ខ្លួនមិនជាប់កាតព្វកិច្ចនឹងកថាខណ្ឌ ១ នៃមាត្រានេះទេ ។ រដ្ឋភាគីឯទៀត នឹងមិនជាប់កាតព្វកិច្ចក្នុងកថាខណ្ឌ ១ នេះ ជាមួយរដ្ឋភាគីណាដែលបានធ្វើល័ក្ខខ័ណ្ឌនេះឡើយ ។

៣. រដ្ឋភាគីណា ដែលធ្វើល័ក្ខខ័ណ្ឌស្របតាមកថាខណ្ឌ ២ នៃមាត្រានេះ អាចដកល័ក្ខខ័ណ្ឌរបស់ខ្លួនវិញគ្រប់ពេល ដោយការជូនដំណឹងជាលាយលក្ខអក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៣០

អនុសញ្ញានេះ ដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃស្មើគ្នា នឹងត្រូវតំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

**ជាបន្ទាល់នៃអនុសញ្ញានេះ** បុណ្ណទូតដែលមានហត្ថលេខាខាងក្រោម ហើយដែលបានទទួលនូវការអនុញ្ញាតយ៉ាងត្រឹមត្រូវ បានចុះហត្ថលេខាលើអនុសញ្ញានេះ ។

-------//-------



Downloaded from http://www.khmerlaws.com